# ក្រុមឃ្លាំមើលសហគមន៍

## ទីក្រុងឡុងប៊ិច

ក្រសួងប៉ូលីសទីក្រុងឡុងប៊ិច

## សំណុំឯកសារចាប់ផ្តើម

## 3 ដំណាក់កាលងាយៗ

នាំមកជូនដោយ
ក្រសួងប៉ូលីសទីក្រុងឡុងប៊ិច
*www.longbeach.gov/police*

# តារាងមាតិកា

## 1 ការសិក្សាស្រាវជ្រាវ


ការស្វាគមន៍ 2

អំពីកម្មវិធីឃ្លាំមើលសហគមន៍ 3

បុគ្គលទំនាក់ទំនង 4


## 2 ការបង្កើត


ទិសដៅ 5

ការចាប់ផ្តើម 6

តួនាទី និងការទទួលខុសត្រូវ 7

ខ្លឹមសារជាសារវន្ត 8

បញ្ជីត្រួតពិនិត្យកិច្ចប្រជុំ 9

ការណែនាំដើម្បីជោគជ័យ 10


## 3 សកម្មភាព


គំរូរបៀបវារៈ 11

គំរូខិត្តប័ណ្ណ 12

គំរូតារាងចុះឈ្មោះ 13

គំរូផែនទី 14 & 15

ឧបករណ៍ និងធនធាន 16

ជូនចំពោះអ្នកស្ម័គ្រចិត្តក្រុមឃ្លាំមើលសហគមន៍ជាទីរាប់អាន!

ទីក្រុងឡុងប៊ិច សូមថ្លែងអំណរគុណចំពោះចំណាប់អារម្មណ៍របស់លោកអ្នកក្នុងការចាប់ផ្តើមដំណើរការក្រុមឃ្លាំមើលសហគមន៍ (CWG) ហើយទីក្រុងឡុងប៊ិចក៏ចង់ជួយធានាឲ្យបាននូវភាពជោគជ័យក្នុងកិច្ចប្រឹងប្រែងរបស់លោកអ្នក។ កម្មវិធីឃ្លាំមើលសហគមន៍ គឺជាកម្មវិធីទប់ស្កាត់ឧក្រិដ្ឋកម្ម ដែលពាក់ព័ន្ធនឹងគ្រប់ទិដ្ឋភាពនៃកិច្ចសហការរបស់សហគមន៍ និងការជួយជំរុញការអនុវត្តច្បាប់ដើម្បីរារាំងបទល្មើសព្រហ្មទណ្ឌ។ CWG ដែលមានឆន្ទៈ និងការរៀបចំត្រឹមត្រូវអាចធ្វើឲ្យមានការផ្លាស់ប្តូរច្រើន ក្នុងការទប់ស្កាត់ និងកាត់បន្ថយបទល្មើសព្រហ្មទណ្ឌនៅក្នុងសង្កាត់របស់ពួកគេ។

ជាទូទៅ CWGs មានសមាជិកចាប់ពី 12 ទៅ 20 លំនៅដ្ឋាន អាជីវកម្ម សាលារៀន និង/ឬ អង្គការសាសនានៅក្នុងសហគមន៍។ យ៉ាងហោចណាស់ ក្រុមនីមួយៗ ត្រូវមានមនុស្សម្នាក់ធ្វើជាប្រធានក្រុម CWG ដែលមានតួនាទីដឹកនាំក្រុមក្នុងការរៀបចំកិច្ចប្រជុំ ការបញ្ចូលសមាជិកថ្មីៗ និងការសហការជាមួយសហគមន៍។

តាមរយៈការសម្របសម្រួលជាមួយអង្គភាពចំណុះកណ្តាលទីក្រុងឡុងប៊ិច ក្រសួងប៉ូលិសទីក្រុងឡុងប៊ិចបានបង្កើតសំណុំឯកសារនេះឡើងដើម្បីផ្តល់ភាពងាយស្រួលក្នុងការរៀបចំ CWG នៅក្នុងសង្កាត់របស់អ្នក។ យើងខ្ញុំ សូមថ្លែងអំណរគុណចំពោះការបន្តគាំទ្ររបស់អ្នក និងការខ្នះខ្នែងធ្វើឲ្យទីក្រុងឡុងប៊ិចក្លាយជាកន្លែងរស់នៅដែលកាន់តែមានសុវត្ថិភាព។ យើងខ្ញុំសង្ឃឹមថានឹងបានធ្វើការជាមួយអ្នក!

សូមមេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះអំពីខ្ញុំ។

Robert G. Luna
នាយប៉ូលិស

# អំពីក្រុមឃ្លាំមើលសហគមន៍

កម្មវិធីឃ្លាំមើលសហគមន៍ គឺជាកម្មវិធីមួយក្នុងចំណោមកម្មវិធីទប់ស្កាត់ឧក្រិដ្ឋកម្ម ដែលត្រូវបានបង្កើតឡើងមុនគេបង្អស់ នៅសហរដ្ឋអាមេរិក។ កម្មវិធីឃ្លាំមើលសហគមន៍ គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាព ពីព្រោះវានាំឲ្យសហគមន៍រួបរួមគ្នាឆ្ពោះទៅកាន់ការអនុវត្តច្បាប់តាមមូលដ្ឋានដើម្បីបង្ក្រាបបទឧក្រិដ្ឋ និងធ្វើឲ្យសហគមន៍កាន់តែមានសុវត្ថិភាព។

ដំណោះស្រាយសហការគ្នា “ពីប្លុកអគារមួយទៅប្លុកអគារមួយ” ប្រឆាំងនឹងបទឧក្រិដ្ឋ គឺជាឱកាសមួយ ដើម្បីស្គាល់អ្នកជិតខាងរបស់អ្នក និងរក្សាការឃ្លាំមើលយ៉ាងជិតដល់នៅតាមដងផ្លូវ និងសហគមន៍របស់អ្នកទាំងមូល។ កម្មវិធីនេះ នឹងបង្រៀនអ្នកអំពីរបៀបដែលធ្វើឱ្យការទប់ស្កាត់បទឧក្រិដ្ឋក្លាយជាទម្លាប់ប្រចាំថ្ងៃរបស់អ្នក តាមរយៈការឃ្លាំមើលគ្នាទៅវិញទៅមក។

កម្មវិធីនេះ មិនតម្រូវឱ្យមានការជួបជុំគ្នាជាញឹកញាប់នោះទេ ហើយក៏មិនស្នើឲ្យនរណាម្នាក់ប្រថុយនឹងគ្រោះថ្នាក់ដែរ។ ដើម្បីទប់ស្កាត់បទឧក្រិដ្ឋ ការងាររបស់អ្នកគឺត្រូវរាយការណ៍អំពីសកម្មភាពសង្ស័យទៅប៉ូលីស ហើយទុកឲ្យប៉ូលីសរកផ្លូវដោះស្រាយជាមួយឧក្រិដ្ឋជន។ មិនតែប៉ុណ្ណោះ កម្មវិធីនេះផ្តល់ឱកាសឲ្យសមាជិកជួបជុំគ្នា និងនិយាយគ្នាដោយផ្ទាល់ជាមួយនឹងមន្ត្រីប៉ូលីសដែលល្បាតនៅក្នុងសង្កាត់របស់ពួកគេ។

ការចូលរួមរបស់អ្នកជិតខាង អាចជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយទប់ស្កាត់ឧក្រិដ្ឋកម្មដ៏មានប្រសិទ្ធភាពបំផុត ដែលអាចអនុវត្តបាន។ តាមរយៈការធ្វើការរួមគ្នាគ្រប់ៗគ្នាអាចជួយប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មប្រកបដោយភាពជោគជ័យបំផុតតាមដែលអាចធ្វើទៅបាន នៅមុនពេលដែលវាចាប់ផ្តើម។

កម្មវិធីឃ្លាំមើលសហគមន៍ មានភាពងាយស្រួលក្នុងការចាប់ផ្តើម និងមានសារៈសំខាន់នៅពេលអនុវត្ត។ តាមរយៈការចាប់ផ្តើមបង្កើតក្រុមឃ្លាំមើលសហគមន៍នៅតំបន់របស់អ្នក អ្នកកំពុងឆ្ពោះទៅរកទិសដៅដ៏ត្រឹមត្រូវ ដែលនឹងធ្វើឲ្យលំនៅដ្ឋាន និងសហគមន៍របស់អ្នកកាន់តែមានសុវត្ថិភាពក្នុងការរស់នៅ។

COMMUNITY WATCH GROUP
CITY OF LONG BEACH
Long Beach Police Department

# បុគ្គលទំនាក់ទំនង

| | |
|---|---|
| **ប៉ូលីសសង្គ្រោះបន្ទាន់ និងអគ្គិភ័យ** | **911** |
| ការបញ្ជូនក្រុមប៉ូលីស/មិនសង្គ្រោះបន្ទាន់/អនាមិក | (562) 435-6711 |
| ទីបញ្ជាការ PD (400 W. Broadway) / ការិយាល័យព័ត៌មាន PD | (562) 570-7260 |
| ទីបញ្ជាការផ្នែកអគ្គិភ័យ (3205 Lakewood Blvd) | (562) 570-2500 |
| ទំនាក់ទំនងផ្ទាល់ពីទូរសព្ទដៃ LBPD | (562) 435-6711 |
| ទំនាក់ទំនងផ្ទាល់ពីទូរសព្ទដៃ LBPD | (562) 436-8211 |

**អង្គភាព LBPD ខាងកើត** lbpdeast@longbeach.gov

**3800 E. Willow Street**

| | |
|---|---|
| បណ្ដាញទូរសព្ទសំខាន់ | (562) 570-5880 |
| នាយប៉ូលីសកម្លាំងល្បាត | (562) 570-5812 |
| អ្នកឯកទេសផ្ដល់សេវាតាមសង្កាត់ | (562) 570-5808 |

**អង្គភាព LBPD ខាងជើង** lbpdnorth@longbeach.gov

**4891 Atlantic Avenue**

| | |
|---|---|
| បណ្ដាញទូរសព្ទសំខាន់ | (562) 570-9800 |
| នាយប៉ូលីសកម្លាំងល្បាត | (562) 570-9827 |
| អ្នកឯកទេសផ្ដល់សេវាតាមសង្កាត់ | (562) 570-9825 |

**អង្គភាព LBPD ខាងលិច** lbpdwest@longbeach.gov

**1835 Atlantic Avenue**

| | |
|---|---|
| បណ្ដាញទូរសព្ទសំខាន់ | (562) 570-3400 |
| នាយប៉ូលីសកម្លាំងល្បាត | (562) 570-3462 |
| អ្នកឯកទេសផ្ដល់សេវាតាមសង្កាត់ | (562) 570-3461 |

**បណ្ដាញទូរសព្ទរាយការណ៍**

| | |
|---|---|
| ថ្នាំញៀន | (562) 570-7125 |
| បណ្ដាញទូរសព្ទឲ្យការណ៍អំពីក្រុមជនពាល | (866) 426-4847 |
| បណ្ដាញទូរសព្ទឲ្យការណ៍អំពីភេរវកម្ម | (562) 570-5593 |
| ការប្ដឹងតវ៉ាអំពីបញ្ហាចរាចរណ៍ | (562) 570-7209 |
| ផ្នែកស៊ើបអង្កេតអនីតិជន | (562) 570-1426 |
| កិច្ចការផ្ទៃក្នុង | (562) 570-7343 |

**ព័ត៌មានបន្ថែមអំពី LBPD**

| | |
|---|---|
| វិបសាយក្រសួងប៉ូលីស | www.longbeach.gov/police |
| ស្ថិតិឧក្រិដ្ឋកម្ម | www.longbeach.gov/police |
| វិបសាយឧក្រិដ្ឋជនផ្លូវភេទ | www.meganslaw.ca.gov |

**តំណាងអាជ្ញាធរក្រុង**

| | |
|---|---|
| ក្រុមប្រឹក្សាសង្កាត់ទី 1 | (562) 570-6919 |
| ក្រុមប្រឹក្សាសង្កាត់ទី 2 | (562) 570-6684 |
| ក្រុមប្រឹក្សាសង្កាត់ទី 3 | (562) 570-6300 |
| ក្រុមប្រឹក្សាសង្កាត់ទី 4 | (562) 570-5508 |
| ក្រុមប្រឹក្សាសង្កាត់ទី 5 | (562) 570-5555 |
| ក្រុមប្រឹក្សាសង្កាត់ទី 6 | (562) 570-6816 |
| ក្រុមប្រឹក្សាសង្កាត់ទី 7 | (562) 570-7777 |
| ក្រុមប្រឹក្សាសង្កាត់ទី 8 | (562) 570-6685 |
| ក្រុមប្រឹក្សាសង្កាត់ទី 9 | (562) 570-6137 |

**សេវាផ្សេងទៀតរបស់ក្រុង** www.longbeach.gov

| | |
|---|---|
| រទេះទិញឥវ៉ាន់ដែលបោះបង់ | (800) 252-4613 |
| សេវាថែទាំសត្វ | (562) 570-PETS (7387) |
| ការអនុវត្តច្បាប់ | (562) 570-CODE (2633) |
| អន្តរាគមន៍បន្ទាន់លើការផ្ទុះឧស្ម័ន | (562) 570-2140 |
| ផ្នែកសម្អាតការគូសវាសលើជញ្ជាំង | (562) 570-2773 |
| ក្រសួងរដ្ឋាករទឹកទីក្រុងឡុងប៊ិច | (562) 570-2390 |
| មណ្ឌលព័ត៌មានសង្កាត់ | (562) 570-1010 |
| ការិយាល័យផ្ដល់សេវាតាមសង្កាត់ | (562) 570-6866 |
| ការអនុវត្តច្បាប់ចំណត | (562) 570-2866 |
| ចំណតរថយន្តគិតលុយតាមម៉ោង | (562) 570-3264 |
| ប្រព័ន្ធលូ | (562) 570-2440 |
| ការប្រមូលសំរាម និងកែច្នៃឡើងវិញ | (562) 570-2876 |
| ស្លាកសញ្ញាចរាចរណ៍ | (562) 570-3264 |
| អំពូលបំភ្លឺតាមផ្លូវ | (562) 983-2000 |

# ទិសដៅ

> *ផ្តល់សិទ្ធិអំណាចដល់សហគមន៍ដើម្បីជួយទប់ស្កាត់ឧក្រិដ្ឋកម្មក្នុងសង្កាត់របស់ខ្លួន។*

## សុវត្ថិភាពផ្ទាល់ខ្លួន

- របៀបជៀសវាងការក្លាយខ្លួនជាជនរងគ្រោះ
- បង្កើនការយល់ដឹងអំពីសុវត្ថិភាពផ្ទាល់ខ្លួននៅផ្ទះ តាមផ្លូវ និងក្នុងពេលធ្វើដំណើរប្រចាំថ្ងៃនៅក្នុងសហគមន៍

## សន្តិសុខលំនៅដ្ឋាន & អាជីវកម្ម

- លើកកម្ពស់ផ្សព្វផ្សាយការអនុវត្តវិធីងាយៗលើការទប់ស្កាត់ចោរកម្ម និងសន្តិសុខលំនៅដ្ឋាន/អាជីវកម្ម

## ទំនាក់ទំនងពេលមានអាសន្ន

- របៀបរាយការណ៍អំពីសកម្មភាពសង្ស័យ និងរបៀបរៀបរាប់អំពីជនសង្ស័យដែលអាចមាន
- ការបង្កើតឧបករណ៍ ឬមធ្យោបាយទំនាក់ទំនងដើម្បីផ្សព្វផ្សាយព័ត៌មាននៅទូទាំងសហគមន៍

## បច្ចេកទេសតាមដានប្រចាំថ្ងៃ

- របៀបដែលឧក្រិដ្ឋជនសម្រេចចិត្តប្រព្រឹត្តទៅលើជនរងគ្រោះ និងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ
- ឧក្រិដ្ឋកម្មទូទៅបំផុតក្នុងតំបន់របស់អ្នក
- ព័ត៌មានបច្ចេកទេសថ្មីៗបំផុតអំពីការទប់ស្កាត់ឧក្រិដ្ឋកម្ម បច្ចេកវិទ្យា ការពារសន្តិសុខសុវត្ថិភាពផ្ទាល់ខ្លួន និងការលួចអត្តសញ្ញាណ។

## គុណភាពជីវិត

- ដោះស្រាយបញ្ហា និងរួមចំណែកធ្វើឲ្យសហគមន៍កាន់តែមានសុវត្ថិភាព
- លើកកម្ពស់ទំនាក់ទំនងរវាងប៉ូលិស និងសហគមន៍ និងការប្រាស្រ័យទាក់ទងគ្នា
- អារម្មណ៍ទទួលបានការការពារសន្តិសុខក្នុងសង្កាត់
- ការប្រុងប្រយ័ត្នទៅវិញទៅមកនៅតាមសហគមន៍

# ការចាប់ផ្តើម

## ☐ កំណត់មេដឹកនាំសំខាន់ៗ

- បុគ្គលដែលព្រួយបារម្ភអំពីសុវត្ថិភាពសហគមន៍ រួមមាន អំពើឧក្រិដ្ឋ អនាម័យ ទិដ្ឋភាព និងទីសាធារណៈ (សូមមើលតួនាទី និងការទទួលខុសត្រូវនៅទំព័រទី 7)

## ☐ កំណត់ព្រំប្រទល់

- 12 ទៅ 20 លំនៅដ្ឋាន អាជីវកម្ម សាលារៀន អង្គការសាសនា។ល។
- ជាទូទៅ មាន 1-2 ប្លុកអគារ

## ☐ កំណត់កាលបរិច្ឆេទកិច្ចប្រជុំលើកទី 1

- កំណត់កាលបរិច្ឆេទកិច្ចប្រជុំជាមុនដោយទុកពេលគ្រប់គ្រាន់ឲ្យប្រជាពលរដ្ឋធ្វើផែនការ
- សម្រេចជ្រើសយកពេលដែលងាយស្រួលដល់សមាជិកភាគច្រើនបំផុត
- សម្រេចលើទីកន្លែង។ ចុះជួបគ្នានៅផ្ទះអ្នកជិតខាងដើម្បីបង្កើតបរិយាកាសងាយស្រួល។
- ទាក់ទងអ្នកឯកទេសផ្តល់សេវាតាមសង្កាត់ (NSS) របស់ LBPD ប្រចាំនៅតំបន់របស់អ្នកដើម្បីស្នើឲ្យតំណាង LBPD ចូលរួមក្នុងកិច្ចប្រជុំរបស់អ្នក។
- សូមមើលបញ្ជីត្រួតពិនិត្យកិច្ចប្រជុំនៅទំព័រ 9

## ☐ បង្កើតរបៀបវារៈ

- ប្រធានបទគួរតែផ្តោតលើសេចក្តីណែនាំ សារៈសំខាន់នៃ CWG និងការចូលរួមរបស់ LBPD។
- ប្រើគំរូឯកសារដែលបានផ្តល់ជូននៅទំព័រ 11

## ☐ បង្កើត & ចែកចាយខិត្តប័ណ្ណ

- ប្រើគំរូឯកសារដែលបានផ្តល់ជូននៅទំព័រ 12
- សាកសួរពីផ្ទះមួយទៅផ្ទះមួយដើម្បីជ្រើសរើសសមាជិក និងការចូលរួម

## ☐ ការប្រាស្រ័យទាក់ទង & ការរៀបចំ

- រំឭកប្រាប់គ្រប់ៗគ្នាអំពីកាលបរិច្ឆេទកិច្ចប្រជុំរយៈពេលពីរថ្ងៃជាមុន
- រៀបចំមធ្យោបាយទំនាក់ទំនងដែលប្រើសម្រាប់រក្សាការទាក់ទងជាមួយសមាជិក (សូមមើលខ្លឹមសារជាសារវ័ន្តនៅទំព័រ 8)
- ប្រើគំរូឯកសារដែលបានផ្តល់ជូន: តារាងចុះឈ្មោះ និងផែនទី

## ☐ កិច្ចប្រជុំលើកទី 1

- សូមមើលបញ្ជីត្រួតពិនិត្យកិច្ចប្រជុំនៅទំព័រ 9

# តួនាទី & ការទទួលខុសត្រូវ

## ទំនាក់ទំនងសហគមន៍របស់ CWG

- ណែនាំខ្លួនឲ្យអ្នកជិតខាងអ្នកបានស្គាល់ដើម្បីទទួលការគាំទ្រ និងការចូលរួមរបស់សមាជិកនៅក្នុងកម្មវិធី។
- ស្វាគមន៍ក្រុមអ្នកចូលមករស់នៅថ្មីៗនៅក្នុងសង្កាត់ និងអញ្ជើញពួកគេឲ្យចូលរួមជាសមាជិកក្រុម
- រៀបចំ និងចែកចាយលិខិតអញ្ជើញចូលរួមកិច្ចប្រជុំ។ រំឭកប្រាប់អ្នកជិតខាងនៅមុនកិច្ចប្រជុំចាប់ផ្តើមបន្តិច។
- រក្សាផែនទីដែលបង្ហាញអំពីឈ្មោះផ្លូវរបស់អ្នក និងលំនៅដ្ឋាន/អាជីវកម្មនីមួយៗ។ កត់ត្រាទុកនូវអាសយដ្ឋាន និងថតចម្លងចែកឲ្យបានគ្រប់ៗគ្នា។ (សូមមើលទំព័រ 14 & 15)
- ឧស្សាហ៍លើកទឹកចិត្តឱ្យមានការចូលរួម និងការបង្កើនចំណេះដឹង។ ធ្វើជាគំរូ ដោយអនុវត្តជាក់ស្តែងលើវិធានការទប់ស្កាត់ឧក្រិដ្ឋកម្ម និងរាយការណ៍ជាបន្ទាន់អំពីករណីសង្ស័យទៅប៉ូលិស។
- ធ្វើជាអ្នកឆ្លើយឆ្លងព័ត៌មានទៅ LBPD និងត្រូវដឹងព័ត៌មានថ្មីៗ
- ប្រមូលព័ត៌មានអំពីបទល្មើសព្រហ្មទណ្ឌ និងផ្សព្វផ្សាយដល់សមាជិក
- ផ្តល់ឲ្យសមាជិកក្រុមនីមួយៗនូវចំណេះដឹងអំពីការទប់ស្កាត់អំពើឧក្រិដ្ឋដែលអាចរកមើលបាននៅលើទំព័រវិបសាយរបស់ LBPD www.longbeach.gov នៅក្រោមផ្នែក "តើខ្ញុំ..."។
- ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំដែលរៀបចំឡើងដោយក្រសួងប៉ូលិស ដើម្បីបន្តឲ្យក្រុមរបស់អ្នកមានឈ្មោះក្នុងបញ្ជី "សកម្ម"។ (មេបញ្ជាការ LBPD ម្នាក់ៗ រៀបចំបើកវេទិកាស្តីពីភាពជាអ្នកដឹកនាំសហគមន៍ប្រចាំត្រីមាស)

## អ្នកចូលរួម

- ត្រូវស្គាល់អ្នកជិតខាង និងកសាងក្រុមការងារសង្កាត់
- ត្រូវមានលក្ខណៈប្រុងប្រយ័ត្ន និងតាមដាន ដោយរាយការណ៍អំពីសកម្មភាពសង្ស័យ ឬអំពើឧក្រិដ្ឋប្រាប់ទៅប៉ូលិសជាបន្ទាន់
- ពិនិត្យមើលគ្រួសារដែលងាយរងគ្រោះ និងផ្តល់ការណែនាំដល់សមាជិកអំពីការដោះស្រាយជាមួយអ្នកស្រែកហៅមាត់ទ្វារ។
- ស្វែងយល់អំពីធនធានសហគមន៍ និន្នាការឧក្រិដ្ឋកម្ម និងការទប់ស្កាត់បទឧក្រិដ្ឋ។
- កំណត់ និងពិភាក្សាអំពីបញ្ហា ឬ កង្វល់ដែលកើតមាននៅក្នុងសង្កាត់ និងជួយបង្កើតផែនការសកម្មភាព។

> *"រក្សាឲ្យមានភាពសកម្ម និងការចូលរួមរបស់សមាជិក។ ត្រូវមានគំនិតច្នៃប្រឌិត និងបង្កើតឲ្យមានតួនាទីសម្រាប់ប្រជាពលរដ្ឋដែលអាស្រ័យលើចំណាប់អារម្មណ៍ និង ជំនាញរបស់ពួកគេ។ គ្រប់ៗគ្នាមានលទ្ធភាពជាច្រើនក្នុងការចូលរួម ដូចជា ការធ្វើកំណត់ហេតុ ការចុះផ្សព្វផ្សាយអំពីការប្រាស្រ័យទាក់ទងគ្នា សមាជិកភាព។ល។"*

COMMUNITY WATCH GROUP
CITY OF LONG BEACH
Long Beach Police Department

# ខ្លឹមសារជាសារវ័ន្ត

> *សមាជិកក្រុមអ្នកឃ្លាំមើលសហគមន៍ មានតួនាទីស្វែងយល់អំពីរបៀបក្លាយខ្លួនជាអ្នកជិតខាងល្អ សាក្សីដ៏សំខាន់ និងរបៀបកំណត់ និងរាយការណ៍សកម្មភាពសង្ស័យ។*

## ផែនទីក្រុមឃ្លាំមើលសហគមន៍

ផែនទីក្រុមឃ្លាំមើលសហគមន៍ (ទំព័រ 14) នឹងជួយឲ្យសមាជិកផ្តល់នូវព័ត៍មានច្បាស់លាស់ នៅពេលរាយការណ៍ព័ត៍មានជនសង្ស័យ ឬមានអាសន្ននៅក្នុងសហគមន៍របស់អ្នក។

- កំណទំនាក់ទំនងសហគមន៍របស់ CWG
- ដាក់ស្លាកឈ្មោះផ្លូវ អាសយដ្ឋាន និងលេខទូរសព្ទនៃអគារនីមួយៗ
- អ្នកកំណត់ប្រភេទបញ្ហាសំខាន់ៗ: ប្រជាពលរដ្ឋចាស់ៗ អ្នកដែលមានបញ្ហាសុខភាព ឬតម្រូវការពិសេសៗ។ល។
- ការចុះបញ្ជីម៉ាក ម៉ូដែល ពណ៌ និងស្លាកលេខរថយន្តរបស់អ្នករស់នៅទីនោះនៅលើផែនទីយានជំនិះរបស់ CW (ទំព័រ 15) នឹងជួយឲ្យអ្នកជិតខាងកំណត់បាននូវប្រភេទយានយន្តដែលសង្ស័យ

## ស្គាល់អ្នកជិតខាងរបស់អ្នក

ការស្គាល់អ្នកជិតខាងរបស់អ្នក និងទម្លាប់ការងារប្រចាំថ្ងៃរបស់ពួកគេកាន់តែច្បាស់ នឹងជួយឲ្យអ្នកដឹងពីសកម្មភាពមិនប្រក្រតី ឬគួរឲ្យសង្ស័យ។ នេះគឺជាព័ត៌មានមូលដ្ឋានដែលគ្រប់ៗគ្នាត្រូវពិចារណាចំពោះការផ្លាស់ប្តូរព័ត៌មានប្រាប់គ្នាទៅវិញទៅមក:

- លំនៅដ្ឋាន ការងារ និងលេខទូរសព្ទដៃ
- អ៊ីម៉ែលនៅផ្ទះ និង/ឬ កន្លែងធ្វើការ
- ចំនួន អាយុ និងឈ្មោះនៃសមាជិកគ្រួសារ ឬ អ្នករស់នៅទីនោះ
- ម៉ោងធ្វើការ
- ម៉ោងចូលរៀន ម៉ោងចូលទៅកន្លែងមើលថែទាំពេលថ្ងៃសម្រាប់កុមារ
- ម្ចាស់សត្វចិញ្ចឹម (ក្នុងករណីមានអគ្គិភ័យ ឬគ្រោះមហន្តរាយធម្មជាតិ)
- វិស្សមកាល ឬភ្ញៀវដែលបានគ្រោងទុក
- ការប្រគល់ទំនិញ ឬការជួសជុលតាមកាលកំណត់

# បញ្ជីត្រួតពិនិត្យ
# ដំណើរការរៀបចំកិច្ចប្រជុំ

- ☐ ត្រូវប្រាកដថា គ្រប់ៗគ្នាបានចុះវត្តមាន
- ☐ ចាត់ឱ្យនរណាម្នាក់សរសេរកំណត់ហេតុ
- ☐ សមាជិកទាំងអស់ គប្បីមានពាក់ស្លាកឈ្មោះ
- ☐ គ្រប់ៗគ្នា គួរតែណែនាំខ្លួន និងប្រាប់ពីកន្លែងស្នាក់នៅ
- ☐ ពន្យល់អំពីសារៈសំខាន់នៃ CWG
- ☐ ពិភាក្សាអំពីកង្វល់នៅតាមសង្កាត់/សហគមន៍
- ☐ សម្រេចចិត្តលើគោលដៅ និងទិសដៅសម្រាប់ក្រុម
- ☐ ឲ្យតំណាងកម្លាំងល្បាតរបស់ LBPD ចូលរួមក្នុងកិច្ចប្រជុំលើកទី 1 របស់អ្នក

> *“នៅកិច្ចប្រជុំលើកទី 1 របស់អ្នក តំណាងកម្លាំងល្បាតរបស់ LBPD នឹងអាចឆ្លើយសំណួរនានាអំពីបទល្មើសព្រហ្មទណ្ឌនៅក្នុងសហគមន៍របស់អ្នក ផ្តល់ការណែនាំអំពីបញ្ហាសុវត្ថិភាព និងពន្យល់អំពីទំនាក់ទំនងរវាង LBPD និង CWGs។”*

# ការណែនាំដើម្បីជោគជ័យ

## មានការចូលរួម

- បញ្ចូលមនុស្សដែលមានប្រវត្តិ និងអាយុខុសៗគ្នាដើម្បីឆ្លុះបញ្ចាំងសហគមន៍ទាំងមូលរបស់អ្នក

## ធ្វើការប្រជុំជាទៀងទាត់

- ធ្វើការប្រជុំជាទៀងទាត់ដើម្បីជួយឲ្យសមាជិកស្គាល់គ្នាទៅវិញទៅមក ហើយសម្រេចចិត្តលើយុទ្ធសាស្ត្រ និងសកម្មភាពនៃកម្មវិធី

## “ក្រុមអ្នកឃ្លាំមើលតាមបង្អួច”

- ស្នើសុំឲ្យអ្នកដែលកម្រចេញពីផ្ទះឲ្យធ្វើជា “អ្នកឃ្លាំមើលតាមបង្អួច” ដែលត្រូវពិនិត្យមើលសង្កាត់ និងរាយការណ៍សកម្មភាពមិនប្រក្រតីនានាក្នុងសង្កាត់។

## ក្រុមអ្នកបកប្រែ

- ត្រូវមានឆន្ទៈបកប្រែព័ត៌មានទាំងអស់ទៅជាភាសានានា ដែលត្រូវការចាំបាច់សម្រាប់អ្នកមិនចេះភាសាអង់គ្លេសនៅក្នុងសហគមន៍របស់អ្នក។ ប្រសិនបើចាំបាច់ ត្រូវមានអ្នកបកប្រែម្នាក់នៅក្នុងកិច្ចប្រជុំ។

## ចូរចងចាំ...
## អ្នកមិនមែនជាប៉ូលីសទេ

- រំឭកសមាជិកថា CWG មិនមែនជាអ្នកការពារ ហើយក៏មិនត្រូវដើរតួនាទីជាប៉ូលីសដែរ។

> *“ការអនុវត្តរបស់ CWG គឺជាវិធីដ៏មានប្រសិទ្ធភាពពិតប្រាកដ ដែលអាចកាត់បន្ថយបទឧក្រិដ្ឋជាច្រើននៅក្នុងសហគមន៍។”*

# ក្រុមឃ្លាំមើលសហគមន៍

## របៀបវារៈ

កាលបរិច្ឆេទ:
ម៉ោង:
ទីកន្លែង:

1. **ចាប់ផ្តើមកិច្ចប្រជុំ និងធ្វើការណែនាំខ្លួន** **5 នាទី**
2. **ប្រធានបទ 1 - ព័ត៌មានថ្មីៗ អំពីឧក្រិដ្ឋកម្ម:**
3. **ប្រធានបទ 2 - ការណែនាំអំពីសុវត្ថិភាព:**
4. **ប្រធានបទ 3 - កង្វល់របស់សហគមន៍:**
5. **ប្រធានបទ 4 - គោលដៅ/យុទ្ធសាស្រ្ត:**
6. **ប្រធានបទ 5 - ព្រឹត្តិការណ៍បន្ទាប់:**
7. **ការងារចាស់**
8. **ការងារថ្មី**
9. **មតិសាធារណៈជន**
10. **ការផ្អាកកិច្ចប្រជុំ**

### កិច្ចប្រជុំបន្ទាប់តាមកាលកំណត់

កាលបរិច្ឆេទ:
ម៉ោង:
ទីកន្លែង:

COMMUNITY WATCH GROUP
CITY OF LONG BEACH

# ក្រុមឃ្លាំមើល សហគមន៍

## កិច្ចប្រជុំ

*ការចូលរួមរបស់អ្នកជិតខាង
គឺជាមធ្យោបាយមួយ
ក្នុងចំណោមមធ្យោបាយ
ទប់ស្កាត់អំពើឧក្រិដ្ឋដ៏មាន
ប្រសិទ្ធភាពបំផុត*

**កាលបរិច្ឆេទ:**

**ទីកន្លែង:**

**ម៉ោង:**

**ប្រធានបទ:**

*សហការគ្នាដើម្បីជួយប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មប្រកប
ដោយភាពជោគជ័យបំផុត...
មុននឹងវាចាប់ផ្តើមកើតឡើង!*


COMMUNITY WATCH GROUP
CITY OF LONG BEACH

# ក្រុមឃ្លាំមើល សហគមន៍

## កិច្ចប្រជុំ

*ការចូលរួមរបស់អ្នកជិតខាង
គឺជាមធ្យោបាយមួយ
ក្នុងចំណោមមធ្យោបាយ
ទប់ស្កាត់អំពើឧក្រិដ្ឋដ៏មាន
ប្រសិទ្ធភាពបំផុត*

**កាលបរិច្ឆេទ:**

**ទីកន្លែង:**

**ម៉ោង:**

**ប្រធានបទ:**

*សហការគ្នាដើម្បីជួយប្រយុទ្ធប្រឆាំង
ឧក្រិដ្ឋកម្មប្រកបដោយភាពជោគជ័យបំផុត...
មុននឹងវាចាប់ផ្តើមកើតឡើង!*

# ក្រុមឃ្លាំមើលសហគមន៍

## បញ្ជីវត្តមាន

*ការចូលរួមរបស់អ្នកជិតខាង គឺជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយទប់ស្កាត់អំពើឧក្រិដ្ឋដ៏មានប្រសិទ្ធភាពបំផុត*

សូមព្រីនឈ្មោះរបស់អ្នកនៅខាងក្រោម (ព្រីនឲ្យច្បាស់)។

| ឈ្មោះ | អាសយដ្ឋាន | ទូរសព្ទ | អ៊ីម៉ែល |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

# ផែនទីក្រុមឃ្លាំមើលសហគមន៍

ផ្លូវ

ឈ្មោះ: ______
#ទូរសព្ទនៅផ្ទះ: ______
#ទូរសព្ទដៃ: ______
អ៊ីម៉ែល: ______
ព័ត៌មាន
ទំនាក់ទំនងបន្ថែម: ______

ឈ្មោះ: ______
#ទូរសព្ទនៅផ្ទះ: ______
#ទូរសព្ទដៃ: ______
អ៊ីម៉ែល: ______
ព័ត៌មាន
ទំនាក់ទំនងបន្ថែម: ______

អាសយដ្ឋាន #

អាសយដ្ឋាន #

ឈ្មោះ: ______
#ទូរសព្ទនៅផ្ទះ: ______
#ទូរសព្ទដៃ: ______
អ៊ីម៉ែល: ______
ព័ត៌មាន
ទំនាក់ទំនងបន្ថែម: ______

ឈ្មោះ: ______
#ទូរសព្ទនៅផ្ទះ: ______
#ទូរសព្ទដៃ: ______
អ៊ីម៉ែល: ______
ព័ត៌មាន
ទំនាក់ទំនងបន្ថែម: ______

អាសយដ្ឋាន #

អាសយដ្ឋាន #

ឈ្មោះ: ______
#ទូរសព្ទនៅផ្ទះ: ______
#ទូរសព្ទដៃ: ______
អ៊ីម៉ែល: ______
ព័ត៌មាន
ទំនាក់ទំនងបន្ថែម: ______

ឈ្មោះ: ______
#ទូរសព្ទនៅផ្ទះ: ______
#ទូរសព្ទដៃ: ______
អ៊ីម៉ែល: ______
ព័ត៌មាន
ទំនាក់ទំនងបន្ថែម: ______

អាសយដ្ឋាន #

អាសយដ្ឋាន #

ឈ្មោះ: ______
#ទូរសព្ទនៅផ្ទះ: ______
#ទូរសព្ទដៃ: ______
អ៊ីម៉ែល: ______
ព័ត៌មាន
ទំនាក់ទំនងបន្ថែម: ______

ផ្លូវ

ឈ្មោះ: ______
#ទូរសព្ទនៅផ្ទះ: ______
#ទូរសព្ទដៃ: ______
អ៊ីម៉ែល: ______
ព័ត៌មាន
ទំនាក់ទំនងបន្ថែម: ______

អាសយដ្ឋាន #

អាសយដ្ឋាន #

ឈ្មោះ: ______
#ទូរសព្ទនៅផ្ទះ: ______
#ទូរសព្ទដៃ: ______
អ៊ីម៉ែល: ______
ព័ត៌មាន
ទំនាក់ទំនងបន្ថែម: ______

ឈ្មោះ: ______
#ទូរសព្ទនៅផ្ទះ: ______
#ទូរសព្ទដៃ: ______
អ៊ីម៉ែល: ______
ព័ត៌មាន
ទំនាក់ទំនងបន្ថែម: ______

អាសយដ្ឋាន #

អាសយដ្ឋាន #

អាសយដ្ឋាន #

អាសយដ្ឋាន #

**ទំនាក់ទំនងសហគមន៍របស់ CWG:**

# ផែនទីយានជំនិះរបស់សហគមន៍




**ទំនាក់ទំនងសហគមន៍របស់ CWG:**

# ឧបករណ៍ និង ធនធាន

## LBPD - កម្មវិធី “GO LBPD”

- ព័ត៌មាន រឿងរ៉ាវ ប្រកាសអាសន្ន ព្រឹត្តិការណ៍ រូបថត និងវីដេអូ
- ការបង្កើតផែនទីឧក្រិដ្ឋកម្ម
- លក្ខណៈពិសេសនៃការណែនាំអំពីឧក្រិដ្ឋកម្មបែបអនាមិក
  *ដើម្បីស្វែងយល់បន្ថែម សូមចូលទៅកាន់វិបសាយ LBPD www.longbeach.gov/police*

## ទីក្រុងឡុងប៊ិច - កម្មវិធី “Go Long Beach”

- លទ្ធភាពចេញចូលសាលាក្រុង 24/7
- ដាក់ពាក្យស្នើសុំសេវាកម្ម – ការគូសវាសលើជញ្ជាំង ជង្ហុកផ្លូវ អំពូលបំភ្លឺខូច ។ល។
  *ដើម្បីទាញយកចូលស្មាតហ្វូនរបស់អ្នក សូមស្វែងរក “Go Long Beach” ដែលមាននៅក្នុងឃ្លាំងកម្មវិធីរបស់អ្នក*

## NIXLE

- សារប្រយ័ត្នសំខាន់ៗ និងឲ្យសញ្ញាភ្លាមៗ ដែលបញ្ជូនដោយ LBPD និង LBFD
- ការបិទផ្លូវ បញ្ហាចរាចរណ៍ ការបាត់មនុស្ស ជនសង្ស័យដែលគ្រោះថ្នាក់។ល។
  *សម្រាប់ព័ត៌មានបន្ថែម ឬដើម្បីចុះឈ្មោះ សូមចូលទៅកាន់វិបសាយ www.nixle.com*

## ភាពជាដៃគូស្ដីពីកាមេរ៉ាសហគមន៍ LBPD

- LBPD អាចមានសិទ្ធិប្រើប្រាស់បណ្ដាញកាមេរ៉ារបស់រដ្ឋ និងឯកជននៅទូទាំងទីក្រុងឡុងប៊ិចដើម្បីពិនិត្យតាមដានបញ្ហាសន្តិសុខតាមរយៈទីក្រុងឡុងប៊ិច រូបភាពប្រតិបត្តិការរួមនៃក្រុងឡុងប៊ិច (LBCOP)
- ក្រុមហ៊ុនឯកជន និងប្រជាពលរដ្ឋមូលដ្ឋាន អាចចូលរួមផ្ដល់សិទ្ធិឲ្យ LBPD ប្រើកាមេរ៉ារបស់ពួកគេ ដើម្បីបើកឲ្យមានការធានារ៉ាប់រងផ្នែកសន្តិសុខកាន់តែទូលំទូលាយនៅទូទាំងទីក្រុង
  *សម្រាប់ព័ត៌មានបន្ថែម ឬដើម្បីចុះឈ្មោះ សូមទាក់ទងនាយប៉ូលិស Eddie Reyes តាមទូរសព្ទលេខ 562-570-7324 ឬ តាមអ៊ីម៉ែល Eduardo.Reyes@longbeach.gov ឬមើលទំព័រវិបសាយតាមតំណwww.longbeach.gov/police/lbcop/*

## ស្ថិតិឧក្រិដ្ឋកម្មនៅក្រុងឡុងប៊ិច

មើលស្ថិតិនៅលើទំព័រវិបសាយរបស់ក្រុងតាមតំណ:
*www.longbeach.gov/police/statistics.asp*

## NEXTDOOR.COM

- ផ្ដល់នូវបណ្ដាញសង្គមឯកជនដោយឥតគិតថ្លៃសម្រាប់អ្នក អ្នកជិតខាង និងសហគមន៍របស់អ្នក
- អ្នកជិតខាងគ្រប់ៗរូបត្រូវផ្ទៀងផ្ទាត់អាសយដ្ឋានរបស់ខ្លួន
- មធ្យោបាយដ៏អស្ចារ្យដើម្បីចែកចាយព័ត៌មានអំពីសកម្មភាពសង្ស័យ កិច្ចប្រជុំ CWG ឬកម្រងអនុសាសន៍
  *សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់វិបសាយ www.nextdoor.com*

## កម្មវិធី GO METRO

- លទ្ធភាពចេញចូលសាលាក្រុង 24/7
- ដាក់ពាក្យស្នើសុំសេវាកម្ម – ការគូសវាសលើជញ្ជាំង ជង្ហុកផ្លូវ អំពូលបំភ្លឺខូច។ល។
- ដាក់ពាក្យស្នើសុំសេវាកម្ម – ការគូសវាសលើជញ្ជាំង ជង្ហុកផ្លូវ អំពូលបំភ្លឺខូច។ល។

# អ្នកកំពុងស្ថិតនៅតាមផ្លូវរបស់អ្នក...

ដោយសារអ្នកបានបង្កើត CWG របស់អ្នកឡើង ការចាប់ផ្តើមដំបូងបំផុតគឺត្រូវស្វែងយល់អំពីវា។ ចំណុចសំខាន់ដើម្បីរក្សា CWG ឱ្យសកម្ម គឺត្រូវរក្សាចំណាប់អារម្មណ៍ជាបន្តបន្ទាប់។ តាមរយៈការធ្វើឲ្យសហគមន៍ទាំងមូលចូលរួម វានឹងបង្កើតមោទនភាព និងភាពជិតស្និទ្ធ។

CWG ដែលសកម្ម អាចធ្វើឲ្យមានការផ្លាស់ប្តូរនៅក្នុងសហគមន៍របស់ពួកគេ ដូចជាការកែលម្អអំពូលបំភ្លឺតាមដងផ្លូវ ចិញ្ចើមថ្នល់ និងផ្លូវចំហៀង។ អ្នកអាចសហការគ្នាបង្កើតគោលការណ៍ ឬការអនុវត្តថ្មីៗដើម្បីបង្កើនសន្តិសុខលំនៅដ្ឋាន។

ធ្វើឲ្យសមាជិក CWG មានភាពរីករាយ និងការពេញចិត្ត។ ត្រូវចាំថា ប្រជាពលរដ្ឋទំនងជានឹងចូលរួម និងមានចំណាប់អារម្មណ៍ច្រើនបំផុត ប្រសិនបើកម្មវិធីនានាមានលក្ខណៈសប្បាយរីករាយ ក៏ដូចជាប្រកបដោយអត្ថន័យ។ ត្រូវមានភាពច្នៃប្រឌិត និងប្រើប្រាស់ការស្រមៃគិតរបស់អ្នក។

ចំពោះសេចក្តីណែនាំ & ឯកសារស្តីពីការទប់ស្កាត់ឧក្រិដ្ឋកម្មសម្រាប់កិច្ចប្រជុំ CWG នាពេលខាងមុខ  សូមចូលទៅកាន់ទំព័រវិបសាយនៃក្រសួងប៉ូលីសក្រុងឡុងប៊ិចតាមតំណ www.longbeach.gov/police ក្រោមផ្នែក “តើខ្ញុំ...យ៉ាងដូចម្តេច”។

***សូមអរគុណ។***